ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតសាលាភូមិន្ទចៅក្រម

* 

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុសញ្ញាហិរញ្ញប្បទាន ខ្មែរ-បារាំង ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០១ ដើម្បីអនុវត្តកម្មវិធីគាំទ្រនីតិរដ្ឋនៅកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តិនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- តាមសំណើរបស់សមាជិកអចិន្ត្រៃយ៍ នៃឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ និងជាប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

# ស ម្រេ ច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

បង្កើតសាលាភូមិន្ទចៅក្រមមួយដែលផ្នែកបច្ចេកទេស ស្ថិតក្រោមអាណាព្យាបាលរបស់ទីស្តីការគណៈរដ្ឋមន្ត្រី និងផ្នែកហិរញ្ញវត្ថុ ស្ថិតក្រោមអាណាព្យាបាលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ២.-**

សាលាភូមិន្ទចៅក្រមជាគ្រឹះស្ថានសាធារណៈរដ្ឋបាល មានស្វ័យភាពរដ្ឋបាល និងហិរញ្ញវត្ថុ ហើយស្ថិតក្រោមវិសាលភាពនៃបទប្បញ្ញត្តិនៃ ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ។

សាលាភូមិន្ទចៅក្រមមានអាសយដ្ឋាននៅផ្លូវឧកញ៉ាជូ ឡុង (ផ្លូវលេខ ៤៦៦) ខ័ណ្ឌចម្ការមន រាជធានីភ្នំពេញ ។

ការផ្លាស់ប្តូរអាសយដ្ឋាននៅពេលខាងមុខ ជាសមត្ថកិច្ចរបស់សាលាភូមិន្ទចៅក្រម ។

**មាត្រា ៣.-**

សាលាភូមិន្ទចៅក្រមជ្រើសរើស និងធានាការប៉ះរង ការបណ្តុះបណ្តាលវិជ្ជាជីវៈចៅក្រម ការបណ្តុះបណ្តាលបន្ត និងវិក្រឹត្យការចៅក្រម និងព្រះរាជអាជ្ញាដែលកំពុងបំពេញការងារនៅសាលាជម្រះក្តីនៃព្រះរាជាណាចក្រ -កម្ពុជា ។

## ជំពូកទី ២

## ការគ្រប់គ្រងសាលាភូមិន្ទចៅក្រម

**មាត្រា ៤.-**

សាលាភូមិន្ទចៅក្រម គ្រប់គ្រងដោយក្រុមប្រឹក្សាភិបាល និងនាយកសាលា ១ រូប ដែលមានអំណាចទូលំទូលាយ ដើម្បីគ្រប់គ្រងគ្រឹះស្ថាន ក្នុងក្របខ័ណ្ឌនៃបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងក្នុងក្របខ័ណ្ឌនៃបទបញ្ជាផ្ទៃក្នុងរបស់សាលា ។

**មាត្រា ៥.-**

ក្រុមប្រឹក្សាភិបាលនៃសាលាភូមិន្ទចៅក្រមមានសមាសភាពដូចតទៅ :

| | |
|---|---|
| ១- ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៣- នាយកសាលាភូមិន្ទចៅក្រម | សមាជិកអចិន្ត្រៃយ៍ |

៤- តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី ១ រូប សមាជិក

៥- តំណាងឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម ១ រូប សមាជិក

៦-តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១ រូប សមាជិក

៧- សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ១ រូប សមាជិក

៨- ចៅក្រមតុលាការកំពូល ១ រូប សមាជិក

៩- ចៅក្រមសាលាឧទ្ធរណ៍ ១ រូប សមាជិក

១០-ចៅក្រមបារាំងជំនាញការនាយក សមាជិកអញ្ជើញ

១១-នាយកការសិក្សាសាលា សមាជិកអញ្ជើញ

សមាជិកអញ្ជើញ ត្រូវបានអញ្ជើញឱ្យចូលរួមក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាល ប៉ុន្តែពុំមានសិទ្ធិធ្វើការបោះឆ្នោតអនុម័តអ្វីឡើយ ។

**មាត្រា ៦.-**

នាយកសាលាភូមិន្ទចៅក្រម ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី ។

នាយកសាលាភូមិន្ទចៅក្រម ត្រូវជ្រើសរើសក្នុងចំណោមចៅក្រម ខាងតុលាការ ឬចៅក្រមខាងអយ្យការ ឬឥស្សរៈជនដែលមានសញ្ញាប័ត្រខ្ពស់ខាងនីតិសាស្ត្រ ។

នាយកសាលាមានបេសកកម្ម ÷

- ធានារ៉ាប់រងដំណើរការរបស់សាលា ដោយអនុវត្តតាមការពិភាក្សាសម្រេចរបស់ក្រុមប្រឹក្សាភិបាល
- អនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល
- ធានារ៉ាប់រងការគោរពវិន័យផ្ទៃក្នុងដែលបានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុង
- តំណាងសាលានៅចំពោះមុខសាលាជម្រះក្ដី និងក្នុងការធ្វើលិខិតទាំងឡាយ ទាក់ទងនឹងជីវភាពស៊ីវិល
- រៀបចំថវិកា គណនីរដ្ឋបាល និងគណនីហិរញ្ញវត្ថុរបស់សាលា
- ជាអាណាប័កលើការចំណាយរបស់សាលាភូមិន្ទចៅក្រម ស្របតាមការប៉ាន់ស្មានថវិកាប្រចាំឆ្នាំ លើកលែងតែថវិកានៃមូលនិធិសាមគ្គីអាទិភាព
- រៀបចំការប្រឡងតាមគោលការណ៍ទូទៅនៃអនាមិកភាព និងកំណែពីរលើកដែលត្រូវបញ្ជាក់ក្នុងបទបញ្ជាផ្ទៃក្នុង
- តែងតាំងគ្រូបណ្ដុះបណ្ដាលក្រៅគ្រឹះស្ថាន និងបុគ្គលិកសាលា
- បង្កើតអង្គការលេខ និងអង្គការចាត់តាំងនៃដំណើរការ និងការគ្រប់គ្រងសាលាភូមិន្ទចៅក្រម
- ធ្វើរបាយការណ៍ប្រចាំឆ្នាំ លើស្ថានភាព សីលធម៌ និងហិរញ្ញវត្ថុ និងគម្រោងការអភិវឌ្ឍរបស់សាលាជូនក្រុមប្រឹក្សាភិបាល
- ចុះហត្ថលេខាលើអនុសញ្ញាផ្សេងៗ ទាក់ទងនិងសេវារដ្ឋបាល សហគ្រាស អង្គការរដ្ឋបាលជាតិ ឬ

បរទេស អង្គការ និងស្ថាប័នអន្តរជាតិនានា បន្ទាប់ពីការផ្តល់យោបល់ឯកភាពពីក្រុមប្រឹក្សាភិបាល និងការយល់ព្រមពីនាយករដ្ឋមន្ត្រី ។

-ធ្វើរបាយការណ៍ប្រចាំឆ្នាំស្តីពីសកម្មភាព ព្រមទាំងដំណើរការរដ្ឋបាល និងហិរញ្ញវត្ថុរបស់សាលា ហើយនិងអំពីគម្រោងការអភិវឌ្ឍទាំងឡាយ ជូនដល់ក្រុមប្រឹក្សាភិបាលមុននឹងបញ្ជូនទៅទីស្តីការគណៈ - រដ្ឋមន្ត្រី ចម្លងជូនក្រសួងយុត្តិធម៌ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

**មាត្រា ៧.-**

ចៅក្រមបារាំងជាជំនាញការនាយក ទទួលបន្ទុកជួយដល់ការងារបណ្តុះបណ្តាល ក្នុងរយៈពេលអនុវត្តគម្រោងមូលនិធិសាមគ្គីអាទិភាព ។

ជំនាញការនាយក គឺជាអាណាប័កតែមួយគត់នៃមូលនិធិសាមគ្គីអាទិភាព ។

ចៅក្រមកម្ពុជា ១ រូបជានាយកសិក្សា។

មន្ត្រីជាន់ខ្ពស់មួយរូប ត្រូវតែងតាំងជាអគ្គលេខាធិការទទួលបន្ទុកការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុរបស់សាលា ។

**មាត្រា ៨.-**

ប្រធាន អនុប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលត្រូវតែងតាំងដោយអនុក្រឹត្យ ។ កាលបើកន្លែងសមាជិកណាមួយនៅទំនេរនោះ ត្រូវតែងតាំងសមាជិកថ្មីជំនួស ។

**មាត្រា ៩.-**

ក្រុមប្រឹក្សាភិបាល ប្រជុំសម្រេចលើបញ្ហាដែលបានស្នើឡើងដោយនាយកសាលា ។ នាយកសាលា ត្រូវផ្តល់យោបល់ជាចាំបាច់ពីបញ្ហាដែលទាក់ទងដល់ការចាត់តាំង និងដំណើរការរបស់សាលា ។

ក្រុមប្រឹក្សាភិបាលមានបេសកកម្ម ÷

- អនុម័តបទបញ្ជាផ្ទៃក្នុងរបស់សាលា កម្មវិធីសិក្សា បែបបទនៃការប្រឡង និងសមាសភាពគណៈមេប្រយោគ
- អនុម័តគម្រោងថវិកា
- ត្រួតពិនិត្យការគ្រប់គ្រងរបស់នាយក និងអនុម័តរបាយការណ៍ប្រចាំឆ្នាំ
- អនុញ្ញាតឱ្យបង្កើតមជ្ឈមណ្ឌលសាខាជំនាញ និងយល់ព្រមលើអនុសញ្ញារវាងសាលាភូមិន្ទចៅក្រមជាមួយនិងគ្រឹះស្ថានជាតិ សេវាជាតិ ឬអន្តរជាតិនានា
- ចាត់តាំងគណៈកម្មាធិការអចិន្ត្រៃយ៍មួយ ឱ្យទទួលបន្ទុកតាមដានកិច្ចការប្រចាំថ្ងៃ
- ប្រជុំពិភាក្សាលើរបាយការណ៍ប្រចាំឆ្នាំទាក់ទងនឹងសកម្មភាព ដំណើរការរដ្ឋបាល និងដំណើរការហិរញ្ញវត្ថុរបស់សាលា មុនបញ្ជូនទៅរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
- តែងតាំងប្រធាន និងសមាជិកគណៈមេប្រយោគសម្រាប់ការប្រឡង។

**មាត្រា ១០.-**

ក្រុមប្រឹក្សាភិបាល ប្រជុំសាមញ្ញនៅសប្តាហ៍ទីមួយនៃខែ ឧសភា និងខែ តុលា និងប្រជុំវិសាមញ្ញតាមសំណើរបស់ប្រធានក្រុមប្រឹក្សាភិបាល នាយកសាលា ឬសមាជិកក្រុមប្រឹក្សាភិបាលចំនួនពាក់កណ្តាល។ លិខិតអញ្ជើញប្រជុំ ត្រូវភ្ជាប់របៀបវារៈប្រជុំមកជាមួយ ។

**មាត្រា ១១.-**

ក្រុមប្រឹក្សាភិបាលអាចប្រជុំបានដរាបណាមានសមាជិកចំនួនពាក់កណ្តាល ។ សេចក្តីសម្រេចត្រូវធ្វើឡើងដោយមតិភាគច្រើននៃសមាជិកដែលមានសិទ្ធិបោះឆ្នោតវត្តមាន ។ ក្នុងករណីដែលមានសំឡេងស្មើគ្នា សំឡេងរបស់ប្រធានមានឧត្តមានុភាព ។

តំណាងរបស់សមាជិកក្រុមប្រឹក្សាភិបាលមិនត្រូវអនុញ្ញាតឱ្យចូលប្រជុំទេ ។

**មាត្រា ១២.-**

ការប្រជុំពិភាក្សារបស់ក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាទុកក្នុងបញ្ជិកាពិសេសមួយ ដែលត្រូវរក្សាទុកនៅសាលាភូមិន្ទចៅក្រម ហើយបញ្ជិកានេះ ត្រូវចុះហត្ថលេខាដោយប្រធាន និងលេខាធិការរបស់អង្គប្រជុំ ។

**មាត្រា ១៣.-**

គណៈកម្មាធិការអចិន្ត្រៃយ៍របស់ក្រុមប្រឹក្សាភិបាលដែលចែងក្នុងមាត្រា ៩ មានសមាសភាព ៥ រូប គឺនាយកសាលា និងសមាជិក ៤ រូបទៀតរបស់ក្រុមប្រឹក្សាភិបាល ដែលត្រូវចាត់តាំងដោយក្រុមប្រឹក្សាភិបាលក្នុងសម័យប្រជុំសាមញ្ញនៅខែឧសភា។

គណៈកម្មាធិការអចិន្ត្រៃយ៍ ត្រូវប្រជុំរាល់សប្តាហ៍នៃចុងខែនីមួយៗ រួចត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាល ។

ក្រុមប្រឹក្សាភិបាល អាចផ្ទេរឱ្យគណៈកម្មាធិការអចិន្ត្រៃយ៍ នូវមុខការមួយចំនួន លើកលែងតែកិច្ចការដែលទាក់ទងនឹងថវិកាប្រចាំឆ្នាំ ការអនុម័តលើគណនី កម្មវិធីសិក្សា និងរបាយការណ៍ប្រចាំឆ្នាំ ។

គណៈកម្មាធិការអចិន្ត្រៃយ៍ រាយការណ៍អំពីសេចក្តីសម្រេចរបស់ខ្លួនជូនក្រុមប្រឹក្សាភិបាលនៅក្នុងអង្គប្រជុំលើកទី ១ របស់ក្រុមប្រឹក្សាភិបាល ។

**មាត្រា ១៤.-**

សាលាភូមិន្ទចៅក្រមត្រូវផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រី និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នូវឯកសារខាងក្រោម ÷

- កំណត់ហេតុប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- ផែនការអភិវឌ្ឍរបស់សាលាភូមិន្ទចៅក្រម
- ថវិកាប្រចាំឆ្នាំ

- របាយការណ៍នៃការគ្រប់គ្រងប្រចាំឆ្នាំ និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ

សំណុំឯកសារទាំងអស់នេះ ត្រូវធ្វើឱ្យដល់គម្យជនក្នុងរយៈពេល ១ ខែ យ៉ាងយូរ បន្ទាប់ពីថ្ងៃប្រជុំ ។

## ជំពូកទី ៣

## ដំណើរការផ្នែកហិរញ្ញវត្ថុ

**មាត្រា ១៥.-**

ការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យរបស់សាលាភូមិន្ទចៅក្រម ត្រូវស្ថិតនៅក្រោមគោលការណ៍នៃគណនេយ្យសាធារណៈ លើការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ និងគណនេយ្យសាធារណៈដែលបានកំណត់ក្នុងមាត្រា ១២២ នៃអនុក្រឹត្យលេខ ៨២ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្ដីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ ។

**មាត្រា ១៦.-**

នាយកសាលាភូមិន្ទចៅក្រម ជាអាណាប័កដើមខ្សែរបស់សាលា ។ ក្នុងន័យនេះនាយកសាលាត្រូវមានភារកិច្ច ៖

- ពិនិត្យប្រាក់ និងទូទាត់ចំណូល
- ចាត់ចែងធ្វើការទូទាត់ និងចេញបញ្ជាចំណាយ ។

ក្នុងការចំណាយរបស់សាលា អាណាប័កដើមខ្សែអាចផ្ដល់សិទ្ធិទៅឱ្យអាណាប័កផ្ទេរសិទ្ធិ ឬអាណាប័កដើមខ្សែអាចបង្កើតផ្នែកគ្រប់គ្រងរដ្ឋទេយ្យចំណូល និងចំណាយដោយមានការយល់ព្រមពីគណនេយ្យករប្រតិស្រុតដែលតែងតាំងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១៧.-**

ប្រតិបត្តិការហិរញ្ញវត្ថុ និងការកាន់កាប់គណនេយ្យ ត្រូវអនុវត្តតាមបទបញ្ជាផ្ទៃក្នុងរបស់សាលាភូមិន្ទចៅក្រម ក្រោមការទទួលខុសត្រូវផ្ទាល់របស់គណនេយ្យករ ដូចមានចែងក្នុងមាត្រា ១៦ខាងលើ ។ គណនេយ្យករត្រូវចូលរួមការប្រជុំរបស់ក្រុមប្រឹក្សាភិបាលក្នុងនាមអ្នកពិគ្រោះយោបល់ ។

**មាត្រា ១៨.-**

គណនេយ្យករត្រូវទទួលបន្ទុក ៖

- ប្រមូលចំណូល
- បើកប្រាក់ចំណាយ
- រក្សាទុក និងចាត់ចែងប្រើប្រាស់នូវមូលនិធិ និងវត្ថុមានតម្លៃ
- រក្សាទុក នូវលិខិតយុត្តិការ និងកាន់បញ្ជីគណនេយ្យ ។

គណនេយ្យករអាចផ្ទេរសិទ្ធិខ្លះឱ្យទៅមន្ត្រីក្នុងការិយាល័យបាន ។

**មាត្រា ១៩.-**

ប្រភពធនធានរបស់សាលាព្រមមាន

- ធនធានដំបូងដែលរដ្ឋផ្តល់ឱ្យនៅពេលចាប់ផ្តើមបង្កើតសាលា
- ឧបត្ថម្ភកធនសម្រាប់ដំណើរការ និងឧបត្ថម្ភកធនជាមូលធនដែលបានកំណត់ក្នុងថវិការដ្ឋ
- អំណោយ ជំនួយ និងអច្ច័យទានដែលសាលាបានទទួល
- ផលនៃការខ្ចី
- ផលនៃការងារ ពាវកាលិក និងសេវាដែលសាលាបានផ្តល់ឱ្យ
- ចំណូលដែលបានមកពីទ្រព្យសម្បត្តិដែលអនុញ្ញាតដោយរាជរដ្ឋាភិបាល ។

**មាត្រា ២០.-**

ចំណូល និងចំណាយជាប្រចាំ និងជាមូលធនរបស់សាលាភូមិន្ទចៅក្រម ត្រូវគ្រោងក្នុងថវិកាប្រចាំឆ្នាំរបស់សាលា ។

ក្រុមប្រឹក្សាភិបាល ត្រូវកំណត់អំពីបែបបទនៃការរៀបចំ ការចាត់ចែង និងការប្រតិបត្តិថវិកា ។ សេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលទាក់ទងនឹងទម្រង់បែបបទនៃការរៀបចំ ការចាត់ចែង និងការប្រតិបត្តិថវិកា ត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ២១.-**

ការងារគណនេយ្យរបស់សាលាភូមិន្ទចៅក្រមរួមមាន ÷

- ឯកសារផ្នែកគណនេយ្យទូទៅត្រូវធ្វើជាពីរច្បាប់ ។ ឯកសារនេះ កត់ត្រានូវប្រតិបត្តិការទាំងឡាយផ្នែកហិរញ្ញវត្ថុ ប្រតិបត្តិការផ្នែករតនាគារ និងប្រតិបត្តិការដែលត្រូវធ្វើជាមួយតតិយជន ។
- បញ្ជីសារពើភ័ណ្ឌអចលនទ្រព្យ រូបធាតុ និងវត្ថុមានតម្លៃ ។

ការងារគណនេយ្យរបស់សាលាត្រូវ ÷

- ស្របតាមការកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គោរពតាមប្លង់គណនេយ្យដែលយល់ព្រមដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ២២.-**

គណនេយ្យករ និងអាណាប័កដើមខ្សែ ត្រូវរៀបចំគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីការគ្រប់គ្រង រួចដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេចយ៉ាងយូរបំផុត ៣ ខែ បន្ទាប់ពីការបិទការិយបរិច្ឆេទគណនេយ្យ ។

មូលនិធិរបស់សាលាភូមិន្ទចៅក្រម គឺជាប្រាក់សាធារណៈដែលចាំបាច់ត្រូវតែតម្កល់ក្នុងគណនីមួយដែលត្រូវបើកនៅរតនាគារជាតិ លើកលែងតែមានបដិប្បញ្ញត្តិដែលយល់ព្រមដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៤
## របបសារពើពន្ធនៃសាលាភូមិន្ទចៅក្រម

**មាត្រា ២៣.-**

លើកលែងតែមានបដិប្បញ្ញត្តិរបស់ច្បាប់ សាលាភូមិន្ទចៅក្រម ត្រូវស្ថិតនៅក្រោមនីតិរូប ចំពោះរបបសារពើពន្ធដូចដែលបានអនុវត្តនៅក្នុងអង្គភាពនានារបស់រដ្ឋ ។

## ជំពូកទី ៥
## ការជ្រើសរើសសិស្សឱ្យចូលរៀនសាលាភូមិន្ទចៅក្រម

**មាត្រា ២៤.-**

ការបានចូលរៀននៅសាលាភូមិន្ទចៅក្រម ត្រូវធ្វើដោយការប្រឡង។ ការប្រឡង ២ បែប ត្រូវរៀបចំឡើងតាមសំណើរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

**មាត្រា ២៥.-**

ការប្រឡងបែបទី ១ គឺត្រូវបើកឱ្យបេក្ខជនដែលមានបរិញ្ញាប័ត្រច្បាប់ ដែលមានអាយុមិនលើសពី ៣០ ឆ្នាំគិតមកដល់ថ្ងៃប្រឡង ។

ចំពោះបេក្ខជនដែលមានសញ្ញាប័ត្រខ្ពស់ជាងបរិញ្ញាប័ត្រ កម្រិតអាយុអតិបរមា គឺ៣៥ ឆ្នាំ គិតមកដល់ថ្ងៃប្រឡង ។

ការប្រឡងប្រជែងបែបទី ២ គឺត្រូវបើកឱ្យមន្ត្រីរាជការគ្រប់ក្រសួង ដែលមានបរិញ្ញាប័ត្រច្បាប់ និងដែលមានអាយុមិនលើសពី ៣៨ ឆ្នាំ គិតមកដល់ថ្ងៃប្រឡង ។ ចំពោះបេក្ខជន ជាមន្ត្រីរាជការដូចពោលខាងលើដែលបានបំពេញការងារចាប់ពី ៥ ឆ្នាំ ឡើងទៅហើយ បេក្ខជននោះនឹងត្រូវបានទទួលពិន្ទុបន្ថែម ១០ % (ដប់ភាគរយ) ជាមុន នៃពិន្ទុសរុបដែលកំណត់ក្នុងការប្រឡង ។

បេក្ខជនម្នាក់អាចអនុញ្ញាតឱ្យប្រឡងចូលសាលាភូមិន្ទចៅក្រមមិនលើសពី ៣ ដងឡើយ ។

រាជរដ្ឋាភិបាល អាចជ្រើសរើសមន្ត្រីរាជការ ដែលមានបរិញ្ញាប័ត្រច្បាប់ និងដែលមានគុណសម្បត្តិការងារខ្ពស់ ចំនួនប្រាំ (៥) រូប ក្នុងជំនាន់នីមួយៗ ឱ្យចូលរៀនក្នុងសាលាភូមិន្ទចៅក្រម ដោយពុំចាំបាច់ឆ្លងកាត់ការប្រឡង ។ ការជ្រើសរើសនេះ ត្រូវតែមានយោបល់យល់ព្រមពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជាមុន ។

**មាត្រា ២៦.-**

ចំនួនកន្លែងដែលត្រូវយក និងការបែងចែកចំនួនកន្លែងសម្រាប់ការប្រឡងបែបទី ១ និងការប្រឡងបែបទី ២ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី បន្ទាប់ពីបានពិគ្រោះជាមួយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

បែបបទនៃការរៀបចំ វិធានទាក់ទងនឹងវិន័យ និងកម្មវិធីនៃវិញ្ញាសានៃការប្រឡងទាំងពីរបែប ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី តាមមតិរបស់ក្រុមប្រឹក្សាភិបាលសាលា ។



6

**មាត្រា ២៧.-**

កិច្ចការរបស់សិស្សត្រូវមានលក្ខណៈជាអនាមិក និងត្រូវកែពីរលើក ។

**មាត្រា ២៨.-**

គណៈមេប្រយោគនៃការប្រឡងនីមួយៗ ត្រូវវាយតម្លៃដោយឯករាជ្យ នូវចំនួនបេក្ខជនដែលត្រូវឆ្លងកាត់វិញ្ញាសាសម្រេច ។ ក្នុងករណីដែលមានសំឡេងស្មើគ្នា សំឡេងរបស់ប្រធានគណៈមេប្រយោគ ជាសំឡេងដែលមានឧត្តមានុភាព ។

**មាត្រា ២៩.-**

បេក្ខជនដែលបានប្រឡងជាប់ មានឋានៈជាសិស្សចៅក្រម ។ បេក្ខជនដែលមិនមែនជាមន្ត្រីរាជការមុនពេលចូលរៀនត្រូវចុះហត្ថលេខាលើការសន្យាបម្រើរដ្ឋក្នុងរយៈពេល ៧ ឆ្នាំ យ៉ាងតិចគិតចាប់ពីកាលបរិច្ឆេទនៃការតែងតាំង ។

## ជំពូកទី ៦
## ការបណ្តុះបណ្តាលវិជ្ជាជីវៈចៅក្រម

**មាត្រា ៣០.-**

សាលាភូមិន្ទចៅក្រមជាសាលាអនុវត្ត ។

សិស្សចៅក្រម ត្រូវទទួលការបណ្តុះបណ្តាលបឋមខាងវិជ្ជាជីវៈដែលមានរយៈពេល ២ ឆ្នាំ ។ ការងារបណ្តុះបណ្តាលនេះ រួមមាន ការបង្រៀនឱ្យយល់ដឹងអំពីបច្ចេកទេសខាងតុលាការ និងការត្រិះរិះពិចារណាលើការិយកម្មនៃការប្រតិបត្តិខាងវិជ្ជាជីវៈ ។ ការធ្វើកម្មសិក្សានៅសាលាជម្រះក្តី គឺជាផ្នែកមួយយ៉ាងសំខាន់នៃពេលវេលាបណ្តុះបណ្តាល ។

សាលាភូមិន្ទចៅក្រមត្រូវរៀបចំឱ្យមានកម្មវិធីសិក្សាបន្ត និងថ្នាក់វិក្រឹត្យការសម្រាប់ចៅក្រម និងព្រះរាជអាជ្ញាដែលកំពុងធ្វើការិយកម្មនៅសាលាជម្រះក្តី តាមបែបផែនដែលត្រូវកំណត់ដោយបទ បញ្ជាផ្ទៃក្នុង ។

ការបង្រៀនត្រូវធ្វើឡើងដោយ ÷

១.គ្រូបណ្តុះបណ្តាលដែលជាអ្នកច្បាប់ ហើយត្រូវទទួលការបំពាក់បំប៉នផ្នែកគរុកោសល្យ ។ គ្រូបណ្តុះបណ្តាលអាចបំពេញមុខងារជាគ្រូពេញម៉ោង ឬដោយមិនពេញម៉ោង ។

២.អ្នកធ្វើសន្និសីទដែលនាយកសាលាអញ្ជើញមក មួយដងមួយកាល ហើយត្រូវទទួលកម្រៃជា ប្រាក់ម៉ោង ។

**មាត្រា ៣១.-**

បន្ទាប់ពីមានយោបល់ឯកភាពពីក្រុមប្រឹក្សាភិបាល និងពីទីស្តីការគណៈរដ្ឋមន្ត្រី នាយកសាលា ត្រូវចាត់តាំងគ្រូកម្មសិក្សាសម្រាប់រយៈពេល ៣ ឆ្នាំ ឱ្យធ្វើជាអ្នកឆ្លើយឆ្លងរបស់សាលាភូមិន្ទចៅក្រមសម្រាប់ការបណ្តុះបណ្តាល ចៅក្រមក្នុងសាលាជម្រះក្តីទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣២.-**

បទប្បញ្ញត្តិដែលទាក់ទងនឹងរបបនៃរយៈពេលសិក្សា ល័ក្ខខ័ណ្ឌនៃការដាក់ពិន្ទុ និងការធ្វើចំណាត់ថ្នាក់ ព្រមទាំងសិទ្ធិ និងកាតព្វកិច្ចសម្រាប់សិស្សចៅក្រម ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង ។

សិស្សចៅក្រមណា ដែលមិនបានបញ្ចប់ការសិក្សា មិនអាចមានលក្ខណសម្បត្តិជាអតីតសិស្សសាលាភូមិន្ទចៅក្រមបានឡើយ ។

**មាត្រា ៣៣.-**

ការចូលរួមក្នុងកិច្ចការទាំងឡាយដែលរៀបចំក្នុងក្របខ័ណ្ឌនៃការបណ្តុះបណ្តាលចៅក្រម ត្រូវបើកទូលាយដល់បុគ្គលទាំងឡាយ ដែលចាប់អារម្មណ៍នឹងកិច្ចការនេះ តាមការសម្រេចរបស់នាយកសាលា ។

**មាត្រា ៣៤.-**

ក្រុមប្រឹក្សាភិបាល ត្រូវបង្កើតគណៈកម្មការវិទ្យាសាស្ត្រ និងគរុកោសល្យ ឱ្យទទួលបន្ទុកផ្តល់យោបល់អំពីកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ បណ្តុះបណ្តាលបន្ត និងវិក្រឹត្យការ ។

**មាត្រា ៣៥.-**

គណៈកម្មការវិទ្យាសាស្ត្រ និងគរុកោសល្យមានសមាសភាព ÷

១. នាយកសាលា ............................................................ប្រធាន

២. ជំនាញការនាយកបារាំង.................................................. សមាជិក

៣.នាយកការសិក្សា........................................................ សមាជិក

៤. សាស្ត្រាចារ្យសកលវិទ្យាល័យ ២ រូប ....................................សមាជិក

៥. ចៅក្រម ២ រូប ..........................................................សមាជិក

៦. គ្រូបណ្តុះបណ្តាល ១ រូប ...............................................សមាជិក

៧. បុគ្គលមានសមត្ថភាព ៣ រូប ............................................ សមាជិក

**មាត្រា ៣៦.-**

គណៈកម្មការវិទ្យាសាស្ត្រ និងគរុកោសល្យ ត្រូវប្រជុំមួយឆ្នាំម្តងយ៉ាងតិច តាមការអញ្ជើញរបស់ប្រធានគណៈកម្មការនេះ ។

## ជំពូកទី ៧

## អវសានប្បញ្ញត្តិ

**មាត្រា ៣៧.-**

បទប្បញ្ញត្តិណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាម ភារកិច្ចរៀង១ខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**និងជាប្រធានឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ**

**ហ៊ុន សែន**

***បានយកសេចក្តីជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី***

***"ដើម្បីសុំហត្ថលេខា"***

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី**

**និងជាសមាជិកអចិន្ត្រៃយ៍ នៃឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ**

**សុខ អាន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣៨
- ឯកសារ-កាលប្បវត្តិ